# គោលការណ៍ណែនាំអំពី
# ការចូលជាសមាជិកខេមបូចា

## ១ តើនរណាខ្លះអាចចូលជាសមាជិកខេមបូចាបាន ?

ដើម្បីអាចចូលជាសមាជិកខេមបូចា លោកអ្នកត្រូវតែមានសញ្ជាតិខ្មែរ និង ត្រូវមានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការប្រតិបត្តិតាមគោលការណ៍វិជ្ជាជីវៈសារព័ត៌មាន និងមិនអាចជាមន្ត្រីរដ្ឋាភិបាល(ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ)ឬ បម្រើការឱ្យគណបក្សនយោបាយណាមួយបានឡើយ ។ លក្ខខណ្ឌក្នុងការចូលជាសមាជិក ត្រូវបានកំណត់ទៅតាមប្រភេទសមាជិកនីមួយៗដូចខាងក្រោម៖

- ☑ **សមាជិកអាជីព** (Professional Member) សម្រាប់បុគ្គលដែលកំពុងប្រកបការងារជាអ្នកសារព័ត៌មានពេញម៉ោង ក្រៅម៉ោង ឬការងារឯករាជ្យ (freelance) ក្នុងវិស័យសារព័ត៌មានឬ ប្រព័ន្ធផ្សព្វផ្សាយ ក្នុងអំឡុងពេលដាក់ពាក្យស្នើសុំចូលជាសមាជិក ។

- ☑ **សមាជិករង** (Associate Member) សម្រាប់បុគ្គលដែលមានឆន្ទៈចំពោះគោលការណ៍សេរីភាពសារព័ត៌មាន ប៉ុន្តែមិនទាន់អាចធ្វើការងារជាអ្នកសារព័ត៌មានអាជីពបាន។ ឧទាហរណ៍ និស្សិតដែលកំពុងរៀនសូត្រជំនាញព័ត៌មាន អ្នកសារព័ត៌មានពលរដ្ឋ អ្នកផលិតមាតិកាបែបព័ត៌មានលើបណ្ដាញសង្គម... ។

- ☑ **សមាជិកស្ថាប័ន** (Institutional Member) សម្រាប់ស្ថាប័នសារព័ត៌មានមិនមែនរដ្ឋាភិបាលអង្គភាពប្រព័ន្ធផ្សព្វផ្សាយគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលជំនាញសារព័ត៌មានដែលចុះបញ្ជីជាផ្លូវការនៅកម្ពុជា និងមានឆន្ទៈគោរពគោលការណ៍សេរីភាពសារព័ត៌មាន។

- ☑ **សមាជិកគាំទ្រ** (Support Member) សម្រាប់អ្នកដែលបរិច្ចាគនូវធនធានផ្សេងៗដូចជាធនធានសម្ភារៈថវិកា និងស្មារតី ដើម្បីគាំទ្រដល់ការបំពេញមុខងាររបស់សមាគម។

## ២ របៀបចុះឈ្មោះ និងដាក់ពាក្យសុំចូលជាសមាជិក

ដើម្បីចុះឈ្មោះចូលជាសមាជិកខេមបូចា លោកអ្នកត្រូវបំពេញពាក្យសុំចូលជាសមាជិក នៅការិយាល័យខេមបូចា ឬដាក់ពាក្យតាមរយៈគេហទំព័រ៖ https://camboja.net/register

## ៣ ការពិនិត្យនិងផ្ទៀងផ្ទាត់លើពាក្យស្នើសុំចូលជាសមាជិក

- ☑ ក្រោយពេលទទួលបានពាក្យសុំចូលជាសមាជិក គណៈកម្មាធិការដែលមានសមាសភាពចំនួន ៣រូបចាត់តាំងដោយគណៈគ្រប់គ្រងនៃខេមបូចានឹងជួបប្រជុំប្រចាំខែ (នៅរៀងរាល់ចុងខែ) ដើម្បីពិនិត្យផ្ទៀងផ្ទាត់ រាល់ព័ត៌មានដែលបានបំពេញដោយបេក្ខជននៅក្នុងពាក្យស្នើសុំចូលជាសមាជិក និងសម្រេចលើពាក្យស្នើសុំទាំងនោះ។

- ☑ គណៈកម្មាធិការនឹងធ្វើការសម្រេចក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ ក្រោយពេលទទួលបានពាក្យស្នើសុំចូលជាសមាជិក។

- ☑ គណៈកម្មាធិការមានសិទ្ធិបដិសេធសំណើសុំចូលជាសមាជិក ប្រសិនបើពិនិត្យឃើញថាបេក្ខជនមិនបានបំពេញតាមលក្ខខណ្ឌ័ និងលក្ខន្តិកៈរបស់ខេមបូចា។

### អំពីគណៈកម្មាធិការ

គណៈកម្មាធិការមានតួនាទីសំខាន់នៅក្នុងការពិនិត្យនិងសម្រេចលើពាក្យសុំចូលសមាជិកខេមបូចា សិក្សាអំពីសាវតាររបស់បេក្ខជនដែលបានដាក់ពាក្យស្នើសុំ និងសម្រេចលើពាក្យស្នើសុំនោះ។ សមាសភាពសមាជិកគណៈកម្មាធិការទាំង ៣រូបរួមមាន៖

១. មន្ត្រីគ្រប់គ្រងកម្មវិធីស្រាវជ្រាវ និង តស៊ូមតិ

២. មន្ត្រីគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព

៣. អ្នកសម្របសម្រួលផ្នែកទំនាក់ទំនង និងកៀរគរធនធាន។

## ៤ ការសម្រេចអនុញ្ញាតឱ្យចូលជាសមាជិក

- ☑ ក្រោយពេលគណៈកម្មាធិការសម្រេចអនុញ្ញាតឱ្យបេក្ខជនណាម្នាក់ចូលជាសមាជិកខេមបូចា នឹងធ្វើការជូនដំណឹងទៅដល់បេក្ខជនតាមមធ្យោបាយផ្សេងៗក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ (ថ្ងៃធ្វើការ)។

- ☑ ក្រោយពេលទទួលបានការជូនដំណឹងអំពីការទទួលស្គាល់ជាសមាជិក  បេក្ខជននឹងត្រូវបង់ប្រាក់សមាជិកភាពនៅក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ ។ សមាជិកដែលមានការលំបាកខ្លាំងផ្នែកហិរញ្ញវត្ថុអាចស្នើសុំមកកាន់ខេមបូចាដោយបំពេញពាក្យសុំលើកលែងការបង់ប្រាក់ក្នុងរយៈពេលបណ្តោះអាសន្នណាមួយ ។

- ☑ សម្រាប់អ្នកដែលមិនត្រូវបានទទួលឱ្យចូលជាសមាជិក គណៈកម្មាធិការនឹងជូនដំណឹងពីការសម្រេចមិនទទួលយកជាសមាជិកតាមមធ្យោបាយផ្សេងៗក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ (ថ្ងៃធ្វើការ) ។

## ៥ ការបង់ប្រាក់សមាជិកភាព

គ្រប់សមាជិកខេមបូចាទាំងអស់មានកាតព្វកិច្ចត្រូវបង់ប្រាក់សមាជិកភាពឱ្យបានទៀងទាត់ និងទទួលបានសិទ្ធិ ជាមួយអត្ថប្រយោជន៍ជាច្រើនទៅតាមប្រភេទនៃសមាជិកភាពរបស់ខ្លួន៖

| **អត្ថប្រយោជន៍ទៅតាមប្រភេទសមាជិកភាព** | **សមាជិកអាជីព**<br>៩៦,០០០រៀល/ឆ្នាំ<br>$24/ឆ្នាំ | **សមាជិករង**<br>៤០,០០០រៀល/ឆ្នាំ<br>$10/ឆ្នាំ | **សមាជិកស្ថាប័ន**<br>៨០,០០០រៀល/ឆ្នាំ<br>$20/ឆ្នាំ<br>(សម្រាប់បុគ្គលិកម្នាក់) | **សមាជិកគាំទ្រ**<br>៤៨,០០០រៀល/ឆ្នាំ<br>$12/ឆ្នាំ |
|---|---|---|---|---|
| ទទួលបានសេវាកម្មគ្រប់ប្រភេទដែលខេមបូចាផ្តល់ជូន | ✓ | ✓ | ✓ | ✗ |
| មានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល | ✓ | ✗ | ✓<br>សម្រាប់តែអ្នកតំណាងស្របច្បាប់ម្នាក់ប៉ុណ្ណោះ | ✗ |
| មានសិទ្ធិឈរឈ្មោះជាក្រុមប្រឹក្សាភិបាល | ✓ | ✗ | ✓<br>សម្រាប់តែអ្នកតំណាងស្របច្បាប់ម្នាក់ប៉ុណ្ណោះ | ✗ |
| មានសិទ្ធិចូលរួមសន្និបាតសមាជិកប្រចាំឆ្នាំរបស់ខេមបូចា | ✓ | ✓ | ✓ | ✓ |
| មានសិទ្ធិចូលរួមកម្មវិធីបង្កើតទំនាក់ទំនងរបស់ខេមបូចា | ✓ | ✓ | ✓ | ✓ |

សមាជិកមានសិទ្ធិជ្រើសរើសការបង់ប្រាក់មួយឆ្នាំម្តង ឬ មួយឆ្នាំពីរដង ទៅតាមលទ្ធភាពរបស់ខ្លួន ។ ការបង់ប្រាក់អាចធ្វើឡើងតាមធនាគារ ឬ បង់ជាក្រដាសប្រាក់ផ្ទាល់នៅការិយាល័យខេមបូចា ។ រាល់ការបង់ប្រាក់នឹងត្រូវបានកត់ត្រាទុកក្នុងបញ្ជីត្រឹមត្រូវ ។

**សេវាកម្មរបស់ខេមបូចាមានដូចជា៖**

- ☑ សេវាសម្របសម្រួលដើម្បីទទួលបានការការពារ និង ការប្រឹក្សាយោបល់ពីមេធាវីដោយឥតគិតថ្លៃរាល់ពេលមានបណ្តឹងទាក់ទងនឹងការបំពេញការងារវិជ្ជាជីវៈសារព័ត៌មាន
- ☑ សេវាប្រឹក្សាយោបល់ផ្នែកសុខភាពផ្លូវចិត្តជាមួយអ្នកជំនាញ
- ☑ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីផ្សេងៗដែលរៀបចំដោយខេមបូចា និងអង្គការដៃគូរបស់ខេមបូចា
- ☑ សន្និបាតសមាជិកប្រចាំឆ្នាំរបស់ខេមបូចា

- ឱកាសទទួលបានថវិកាដើម្បីផលិត និងផ្សព្វផ្សាយព័ត៌មាននៅលើគេហទំព័រព័ត៌មានខេមបូចា
- ប័ណ្ណសម្គាល់សមាជិក
- ការជួយសម្របសម្រួលដើម្បីទទួលបានប័ណ្ណសម្គាល់អ្នកសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ។

**បញ្ជាក់៖** សេវាកម្មទាំងនេះនឹងផ្តល់ជូនទៅតាមលទ្ធភាពរបស់ស្ថាប័ន។

## ៦ ការបញ្ឈប់សមាជិកភាព

**ខេមបូចាអាចបញ្ចប់សមាជិកភាពរបស់សមាជិក ក្រោមមូលហេតុណាមួយក្នុងចំណោមមូលហេតុដូចខាងក្រោម៖**

- ទទួលបានការស្នើសុំបញ្ចប់សមាជិកភាពពីសំណាក់សាមីខ្លួន
- សមាជិកមិនបានបង់ប្រាក់សមាជិកភាព (ក្នុងរយៈពេល ៣ខែ)
- ប្តូរការងារថ្មីដែលមិនស្ថិតក្នុងវិស័យព័ត៌មាន និង ខុសពីលក្ខន្តិកៈចែងដោយខេមបូចា
- ត្រូវបានរកឃើញថា បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ដែលប្រាសចាកពីក្រមសីលធម៌ និងគោលការណ៍វិជ្ជាជីវៈអ្នកសារព័ត៌មានឬ ប៉ះពាល់ដល់ប្រយោជន៍រួមរបស់ស្ថាប័ន

គណៈកម្មាធិការទទួលបន្ទុកសមាជិកភាពត្រូវជូនដំណឹងអំពីការសម្រេចបញ្ចប់សមាជិកភាពរបស់នរណាម្នាក់ទៅសាមីខ្លួនជាលាយលក្ខណ៍អក្សរ។

## ៧ ការផ្សព្វផ្សាយពីសមាជិកភាព

ខេមបូចាអាចប្រកាសជាសាធារណៈតាមរយៈគេហទំព័រ និងបណ្តាញសង្គមរបស់ខ្លួនអំពីការទទួលយកបេក្ខជនណាម្នាក់ជាសមាជិករបស់ខេមបូចា លុះត្រាតែទទួលបានការឯកភាពពីសាមីខ្លួន។ រាល់ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសមាជិកត្រូវបានរក្សាការណ៍សម្ងាត់ ដរាបណាមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីសាមីខ្លួនក្នុងការបង្ហាញជាសាធារណៈពីសមាជិកភាពរបស់ខ្លួនទេ។

### សម្រាប់ព័ត៌មានបន្ថែម ទំនាក់ទំនង ៖


កញ្ញា ហុក លីកា ជំនួយការផ្នែកទំនាក់ទំនង និងសមាជិកភាព

098 62 57 11 communications@camboja.net